**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៤៣៧៣ ប្រក.

# ប្រកាស
# ស្តីពី
# ការលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៧/០០៧ចុះថ្ងៃទី២៨ខែកក្កដាឆ្នាំ២០១៧ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនិងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងសាលដីកាលេខ ៣២២ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៣ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៤ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៥ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៦ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៧ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៨ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣២៩ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងសាលដីកាលេខ ៣៣០ (ធ) ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់តុលាការកំពូល

## សម្រេច

**ប្រការ ១ _**

ត្រូវបានលុបឈ្មោះ **គណបក្សចំនួន៩ (ប្រាំបួន)** ចេញពីបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ តាមសាលដីការបស់តុលាការកំពូល ដែលមានរាយឈ្មោះដូចខាងក្រោម៖

១. គណបក្សសង្គមថ្មី

២. គណបក្សស្ត្រីសង្គ្រោះកម្ពុជា

៣. គណបក្សនាងនាគនារីខ្មែរ

៤. គណបក្សពលរដ្ឋខ្មែរ

៥. គណបក្សខ្មែរជាតិនិយម

៦. គណបក្សសង្គមខ្មែរនិយម

៧. គណបក្សពន្លឺសេរីភាព លោក ថាច់ រ៉េង

៨. គណបក្សសេរីបង្រួបបង្រួមជាតិ

៩. គណបក្សប្រជាជាតិខ្មែរ។

**ប្រការ ២ _**

បទប្បញ្ញត្តិទាំងឡាយណាដែលខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣ _**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អង្គភាពនានាចំណុះក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងសាមីគណបក្សត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- ឯកសារ - កាលប្បវត្តិ
- រាជកិច្ច